ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ....៤០៤២......អពដ

GENERAL DEPARTMENT OF TAXATION

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៤

**សូមគោរពជូន**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

**ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចវិបុលសេនាភក្តី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !**

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំសូមចូលរួមអបអរសាទរដោយស្មោះប្រកបដោយមនោសញ្ចេតនារីករាយក្រៃលែងចំពោះសម្តេច ក្នុងឱកាសដែលព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទាននូវគោរមងារជា **សម្តេចវិបុលសេនាភក្តី** តាមព្រះរាជក្រឹត្យ នស/រកត/០៦១៥/៦៣៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៥ ថ្មីៗនេះ។

ព្រះរាជគោរមងារ **សម្តេចវិបុលសេនាភក្តី** ដែលព្រះករុណាជាអម្ចាស់តម្កល់លើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រទានជូននាឱកាសនេះ ពិតជាស័ក្តិសមនឹងគុណបំណាច់ដ៏ឧត្តុង្គឧត្តមរបស់សម្តេច ដែលបាននិងកំពុងពលិកម្មសព្វបែបយ៉ាង ដើម្បីបុព្វហេតុប្រជាជាតិ សាសនា ព្រះមហាក្សត្រ និងក្នុងបំណងស្វែងរកសុខសន្តិភាព ភាពសម្បូណ៌រុងរឿង និងអភិវឌ្ឍន៍ជាតិលើគ្រប់វិស័យ។

ជាថ្មីម្តងទៀត ខ្ញុំបាទយើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេព្តាថែរក្សាព្រះរាជាណាចក្រកម្ពុជា សូមតាមបីបាច់ថែរក្សារ ប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរ ជូនសម្តេចវិបុលសេនាភក្តី ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ បុត្រា បុត្រី ចៅប្រុស ចៅស្រី សូមបានសមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមសម្តេចវិបុលសេនាភក្តី មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុត ពីខ្ញុំ

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន ពន្ធដារ

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្សី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh